សុខ_សុត្ថាល
សាស្ត្រាចារ្យបរិញ្ញា

# មហាត្មៈគន្ធី

ដោះស្រាយវិបត្តិដោយ

# ឧស្សាហៈវិជ្ជាអហិង្សា



សម្រាប់កម្មវិធីសិក្សាគ្រប់ថ្នាក់

.4
២

# អារម្ភកថា

អស់លោកអ្នកអានជាទីគោរព !

នេះជាស្នាដៃថ្មីមួយទៀតបន្ទាប់ពីរឿង «មហាទស្សនវិទូ និងទស្សនវិជ្ជាក្នុងលោក » ទាំងពីរខ្សែរបស់ខ្ញុំដែលបានផ្សាយជូនរួចហើយ ។

ខ្ញុំបាទសេចក្តីបាមោជ្ជ នៅក្នុងអារម្មណ៍ពិតឥតឧបមា ដោយឃើញអស់លោក អ្នកនាង កញ្ញា សិស្សានុសិស្ស និស្សិត បញ្ញាវ័ន្ត នាំគ្នាចាប់អារម្មណ៍ទៅលើអក្សរសាស្ត្រផ្នែក **«ទស្សនវិជ្ជា»** រហូតដល់ទៅជួយគាំទ្រវណ្ណកម្មប្រភេទនេះ អោយមានស្លាបហើរទៅរកជោគជ័យយ៉ាងធំហួសពីការស្មានទុករបស់ខ្ញុំអ្នកនិពន្ធ ។

លើកនេះ ស្នាដៃដែលខ្ញុំបានប្រសិទ្ធិនាមថា «មហាត្មៈគន្ធី ដោះស្រាយវិបត្តិដោយទស្សនវិជ្ជាអហិង្សា» បានចេញជារូបរាងបង្ហាញអាត្មាជាថ្មីម្តងទៀតហើយ ។

រឿងរ៉ាវស្តីពីជីវប្រវត្តិរបស់ **«មហាត្មគន្ធី»** លោកអ្នកនិពន្ធ **«រ៉េយ ម៉ុក»** បានបកប្រែរៀបរៀងម្តងមកហើយ នៅក្នុងឆ្នាំ ១៩៥២ ។

វណ្ណកម្មលោកបាននិយាយរៀបរាប់ពី «**ជីវប្រវត្តិ**» និងសកម្មភាពខ្លះៗរបស់មហាត្មៈគន្ធី» ប៉ុណ្ណោះ ឯចំណែក«**ទស្សនវិជ្ជារបស់លោក**» ប៉ុណ្ណោះ ឯចំណែក «**ទស្សនវិជ្ជារបស់លោក**» នៅពុំទាន់មានអស់លោកអ្នកនិពន្ធណាម្នាក់ចាប់សរសេរនៅឡើយ ។ អាស្រ័យហេតុនេះ ខ្ញុំក៏បានសម្រេចចិត្តជា និងខំស្រាវជ្រាវបកប្រែចងក្រងនូវ «**ទស្សនវិជ្ជាអហិង្សារបស់មហាត្មៈគន្ធី**» ( LA PHILOSOPHIE DE LA NON VIOLENCE DE GANDHI ) នេះអោយមានជារូបរាងឡើង ។

សូមអោយវណ្ណកម្មថ្មីនេះ កានទៅជាអ្នកបំរើដ៏ល្អមួយ របស់អស់លោកអ្នកអានកុំបីល្អៀងឃ្លាតឡើយ ៕

ភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៦

សុខ សុត្តាលេ

សាស្ត្រាចារ្យបរិញ្ញា

# អ្នកនិពន្ធដែលបានសរសេរ
# ទស្សនវិជ្ជារបស់មហាត្មៈគន្ធី

## BIBLIOGRAPHIE


- RENE de BERVAL «LA VIE de MAHATHMA GANHI»
- ROMAIN-ROLAND «GANDHI, ANDREWS et TAGORE»
- GEORGES DUHAMEL «LA MORT de GANDHI»
- F. de MIOMANDRE «LA LEÇON de GANDHI»
- P.MASSON OURSEL «GANDHI un SAINT OU UN SAGE»
- J.FILLIOZAT « LA LEÇON de GANDHI »
- J.ROUSSELNT « NOUS AVONS TUE GAN DHI »
- LOUIS-GUILLAUME «ADIEU au MAHATHMAGANDHI»
- PIERRE-BOUJUT « Ce qui reste après Sa MORT » BAY-BUK « MAHA THMA-GANDHI le Grand Héros indien »
- RABINDRANATH-TAGORE « GANDHI-MAHARAJ »
- Pandit JAWAHARLAL-NEHRU « Le Soleil s'est éteint »
- SURIN-ROY « LA VOIE de GANDHI et son AVENIR »
- DOAN-QUAN-TAN « GANDHI consolation et dése spoir du monde »

- TRAN-VAN HOAN « GANDHI n'est pas mort »
- TRAN-VAN HOAN « GANDHI n' est pas mort »
- G. VIAL MAZET « GANDHI un indien »
- DA J. MARTINIE « AHIMSA »
- ROBERT de CROIX « SYMBOLISME de GANDHI »

# វាយកុំព្យូទ័រដោយ សេវាមិត្តភាព

ផ្ទះលេខ ១៩៤ អិ ផ្សារអូរឫស្សីចាស់ (ផ្លូវសុកហុក)
អាចទទួលវាយអត្ថបទ សៀវភៅសិក្សាគ្រប់ប្រភេទ

# មហាត្មៈគន្ធី ទស្សនវិទូ អហិង្សា

មហាត្មៈគន្ធីជាកូនពៅរបស់លោកក្រមចន្ទគន្ធី និងនាងបុត្លីមៃ នាងត្រកូលបានីយ៉ា គឺត្រកូលអ្នកជំនួញ ។ លោកកើតនៅក្រុងកាទីយ៉ាវ៉ារ រដ្ឋប៉ូប៊ែងដែរ អាត់ល្វេងសមុទ្រថ្ងៃទី ២ តុលា គ. ស ១៨៦៩ ។

ដោយមាតាបិតាឥណ្ឌាសម័យនេះ តែងនិយមដណ្តឹងកូនទុកតាំងតែពីកុមារនេះ លុះអាយុបាន ៣ឆ្នាំ មាតាបិតាមហាត្មៈក៏បានផ្សំផ្គុំលោកនិងកុមារីម្នាក់អាយុ ១០ឆ្នាំ ឈ្មោះនាង កាស្ទូរបៃគន្ធី ។ តើមហាត្មៈគន្ធីមានកូនប៉ុន្មាននាក់ ? នេះជារឿងអាថ៌កំបាំងសម្រាប់ជីវិតរបស់លោក, ព្រោះថាក្រៅពីបុត្តធីតារបស់លោកបង្កើត, មហាត្មៈបានសុំកូននៃវណ្ណៈទាំងបួនយកមកចិញ្ចឹមទុកជាកូនលោក ប្រៀបបាននឹងសមុទ្រដែលបើកចាំទទួលទឹកនៃទន្លេទាំង ៤ដែលមានពណ៌ និងរសជាតិផ្សេងគ្នា, អោយក្លាយទៅជាមានពណ៌និងរសជាតិតែមួយ ។

មហាត្មៈឃើញប្រជាជនឥណ្ឌាកំពុងជាប់ទ្រុង នៃទុក្ខនិងការជិះជាន់តាមរយៈវណ្ណៈទាំងបួននោះផង ហើយវណ្ណៈទាំង ៤នោះ ស៊ុបុត

ជ្រៅទៅក្នុងចិត្តគំនិតនៃប្រជានិករផង ប្រៀបដូចជាជ្រលងនៃទន្លេបួន ស៊ីផ្ទៃដីឥណ្ឌា លោកក៏បានព្យាយាមផ្សាយដំបូន្មានក៏ប្រកបដោយហេតុផល ដើម្បីដោះជំនឿរាស្ត្រពីលទ្ធិខុះហេតុផល ។ ហេតុដូច្នេះហើយបានជាត្ថះគន្ធី សុំកូនស្រីនៃវណ្ណៈចណ្ឌាល របស់មហាត្មះមកធ្វើជាកូនរបស់លោក បានធ្វើអោយប្រជាជនឥណ្ឌាភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

សព្វថ្ងៃនេះរូបភាពរបស់លោកគន្ធី ត្រូវគេយកទៅគោរពបូជាទុកដូចជាអវតានៃព្រះវិស្ណុ ។ ឆាយារបស់លោកដែលគេព្យួរនៅនិងជញ្ជាំងការិយាល័យ ឬគេហដ្ឋានពុំមែនគ្រាន់តែជាគ្រឿងលំអរ ឬជាបូជនិយវត្ថុប៉ុណ្ណោះទេ តែជានិមិត្តរូបនៃសីលធម៌ខាងនយោបាយនិងទស្សនវិជ្ជា វិហឹសាវិតក្កៈ ( Renoncement de toute viloence ) ទៀតផង ។

សីលធម៌, មនុស្សធម៌របស់មហាបុរសគន្ធីបានត្រូវចំណេតក្នុងសាកលលោក លើកអោយខ្ពស់ពីគុណធម៌ទាំងឡាយ ទាំងពួងអាស្រ័យត្បូងនៃសច្ចះភាព ដែលលោកគន្ធីតែងប្រសិទ្ធិនាមថា «សត្យគ្រហះ» ឬដែនដីនៃពាក្យសច្ចះ ។ បើយើងក្រឡេកមើលមករូបលក្ខណះរបស់គន្ធីនោះ យើងនិងឃើញថា លោកពុំមែនជាបុគ្គលគួរអោយប្លែកឡើយ ។ ព្រោះលោករ៉ូមាំងរុល្លង់បានពោលថា មហាត្មះ

មានភ្នែកស្រទុំបញ្ចាក់នូវសេចក្តីសណ្តោសឥតព្រំដែន ។ លោកជាមនុស្សមានទ្រង់ទ្រាយតូចស្គម, មុខឆ្អឹង, ស្លឹកត្រចៀកកន្ទែកចេញពីសងខាងក្បាល ។ លោកចូលចិត្តពាក់មួកម្នូលធ្វើពីសំពត់ ហើយគ្របដណ្តប់សពាង្គកាយដោយសំពត់សងរាប់ឥតគ្រាត ។ ដើរទៅណាមកណាដោយជើងទទេ ។

លោកមិនសូវគិតពីរូបកាយលោកទេ ឥរិយាបថលោកឥតចំណាប់ចិត្តទុកខ្លួនទទេ ស្លៀកតែសំពត់អង្គុយពែនភ្នែនធ្វើសមាធិនៅលើកម្រាលចំបើងមួយ ។

ជាបុគ្គលមានសម្បុរប្រផេះ, មានកម្លាំងខ្សោយ, ជាមនុស្សសាមញ្ញ, ស្លូត សូម្បីបច្ចាមិត្ររបស់លោកក៏លោកមិនប្រកាន់ តែផ្ទុយទៅវិញលោកតែងគោរពគួរសម ហើយមានចិត្តស្មោះស្ម័គ្រជានិច្ច ។ មហាត្មះជាបុគ្គលមានចិត្តធួន់, ហើយចូលចិត្តតែទីកន្លែងស្ងប់ស្ងាត់ ។ លោកតែងទាញចិត្តរបស់លោកពីក្នុងខ្លួនមកក្រៅ ហើយធ្វើការត្រិះរិះ ។

លោកមិនដែលធ្វើឫកពារអោយអ្នកផងកោតខ្លាចទេ។ លោកមិនសូវចេះប្រែប្រួលឥរិយាបថដូចជនទាំងឡាយឡើយ ហើយមានទឹកមុខញញឹមជានិច្ច ។

ថ្វីបើលោកបានចូលរៀន នៅមហាវិទ្យាល័យជាច្រើនក្នុងអាយុ ១៩ ឆ្នាំ ក៏លោកពុំដែលអួតអាង ពីចំណេះវិជ្ជាអោយអ្នកផងគេពន្លាតលោកឡើយ ។ អាទិទេពនៃជនសាសនាដែលត្រូវសារលោកបានគោរព ជាច្រើនតំណរមកហើយនោះ បានអោយតម្លៃទៅលើព្រហ្មវិហារធម៌ ពុំមែនយកប្រាជ្ញាជាមូលដ្ឋានទេ ។ ចិត្តរបស់លោកត្រជាក់ណាស់ ហេតុដូច្នេះហើយបានជាមហាត្មៈសង់អាស្រមរបស់លោកនៅមាត់ស្ទឹង ជាទីដែលធម្មជាតិតែងផ្តល់នូវធាតុអាកាសត្រជាក់គ្រប់ពេលវេលា ។ អាស្រមនោះសង់ដោយដីភក់លាយចំបើងដីបូលប្រក់ក្បឿង ។

ថ្មភក់លាយចំបើងមានបែបជាថ្មពីរ៉ាមីត្រ ប្រទេសអេហ្ស៊ីព ( EGYPE ) ។ អាស្រមបទរបស់មហាត្មៈជារមណីយដ្ឋានដែលប្រតិស្ឋឡើងនៅមាត់ស្ទឹង សបាវមទីជាតំបន់ដែលទឹកអម្រិតនៃពីរអរវេល្លិ ហូរទម្លាក់ខ្លួនមកគ្រប់រដូវទាំងបួន ។

ព្រឹក្សាលតាវល្លិ៍ដែលមនុស្សលោកពុំដែលស្គាល់បាន នៅជុំលំអរហែរតាមដៃស្ទឹង ព្រមទាំងគ្របដណ្តប់អាស្រមបទនេះអោយរិតតែមានសភាពត្រជាក់ត្រជុំថែមទៀតផង ។

លោកស្រូមាំងរុល្លង់បាននិយាយថា លំនៅរបស់លោកមហាត្មៈជាទេវឋាននៃអវតារព្រះភគវ័ត សាងឡើងដើម្បីបំពេញតាបះយោគ

( YOGA ) ។ ជាការពិតណាស់ព្រោះថាម្រឹគនិងបក្សាបក្សីទាំងឡាយ រត់ពពាក់ពពូន នាំគ្នាចុះមកផឹកទឹក ឬស៊ីស្មៅ ដោយសន្តិភាព ។

គេពុំដែលឃើញមានព្រានប្រមាញ់ឯណាម្នាក់ ចូលមកយាយី ដល់ប្រជាជននៃទេវឋាននេះ សូម្បីតែគ្រឿងឧបករណ៍របស់ខ្លួន ក៏គេពុំហ៊ានយកចូលទៅក្នុងបរិវេណនៃអាទិទេពនេះផង ។ ថាទឹកទន្លេគង្គាចុះត្រជាក់ ទឹកចិត្តមហាត្មៈត្រជាក់ជាងវារីនេះទៅទៀត ។ ឯសត្វសាហាវមាន ខ្លា, ដំរី, ជ្រូកព្រៃ ។ សឹងគេចវេះចុះទៅរស់នៅតាមទីវាល អាហ្វេទ័ពទាំងអស់ទុកឱកាសអោយអាពារី អែអូដ, ឈ្លូះ, ប្រើស, របាំង, ក្តាន់ បណ្តើរកូនយ៉ាងសប្បាយ ។ ក្រៅពីនេះបក្សាបក្សី សកុណីជាច្រើនបានមកកាច់សំបុក ទុកកូនតាមចន្លោះវល្លិ៍ដែលផុះរយោនរយានធ្លាក់ចុះមកពីមែកឈើ ។

យើងឃើញថាមហាត្មៈស្រឡាញ់ និងចូលចិត្តរស់នៅក្នុងធម្មជាតិស្ងប់ស្ងាត់ដូចទស្សនវិទូរូស្សូ ( J. Rousseau ) ដែរ ។ តែផ្ទុយទៅវិញលោកពុំបានស្អប់សង្គមមនុស្សរហូតដល់ទៅបោះបង់ចោល ឬដាក់កំហុសទៅលើសង្គមនោះខ្លាំងពេកទេ ។ លោកគន្ធីស្រឡាញ់ពាក្យសច្ចៈ ជាងជីវិត ហើយលោកមិនដែលពោលពាក្យកុហកទេ ។

លោក រ៉ាយ ប៊ុក បានពោលថា ÷

«មហាត្មៈគន្ធី ភ្ញាក់ពីនិទ្រាវេលាម៉ោង ៤កន្លះ រួចលោកថ្វាយបង្គំព្រះ សូត្រធម៌ហើយទើបលោកដើរ ។ សិរិយាបទដើរនេះជាកិច្ចវត្តមួយដែលលោកតែងនិយមប្រើ : ទាំងកិច្ចសូត្រធម៌ គឺត្រូវសូត្រពីពេលវេលាបុព្វណ្ហសម័យ គឺមុនថ្ងៃរះម្តង និងសាយណ្ហសម័យគឺថ្ងៃលិចម្តង ។»

មហាត្មៈមានជំនឿទៅលើត្បូនខ្មាត នព្វគ្រោះពោលគឺ នៅថ្ងៃច័ន្ទលោកនៅស្ងៀមឥតពេលស្តីអ្វីឡើយ សូម្បីមានហេតុការណ៍ធំចំពោះមាតុប្រទេស ឬចំពោះខ្លួន ក៏លោកមិនស្តីនិយាយសោះឡើយ ។

លោកចង់សម្រាន្តលក់វេលាណាក៏លក់ភ្លាម ចង់ភ្ញាក់ពេលណាក៏ភ្ញាក់ភ្លាម ទោះបីមានសម្លេងគឹកកងរំពងយ៉ាងណាក៏ដោយ ។

ទ្វារនៃវិញ្ញាណទាំងប្រាំរបស់លោកបានរម្ងាប់រួចហើយ គ្មានអ្វីអាចមកបណ្តាលអោយគ្រឿងវិញ្ញាណនោះរស់ឡើងវិញ ក្នុងផ្លូវអវិជ្ជាបានឡើយ ។

លោកចូលចិត្តត្រាំទឹកក្តៅរវាង ៤០នាទី ហើយបរិភោគតែអាហារណាដែលស្រួលដល់ការរំលាយអាហារ ។

លោកតែងបារម្ភដូសមនុស្សដែលល្មោភស៊ី ហេតុដូច្នេះបានជាលោកតាំងចិត្តប្តេជ្ញាថា, ក្រោយពេលព្រះអាទិត្យអស្តង្គត លោក

មិនបរិភោគអាហារអ្វីឡើយ ។ លោកមិនព្រមប្រើកាំបិតសមទេ លោកបរិភោគអាហារតាមទម្លាប់ឥណ្ឌា គឺបរិភោគដោយមេដៃ និងម្រាមបន្ទាប់ តែមិនប្រើដៃឆ្វេងពាល់អាហារទេ ។

លោក រ៉ាយ ប៊ុក ពោលថា : មហាត្មៈគន្ធីជាបុគ្គលប្រឆាំងនិងលទ្ធិគ្រឿងចក្រនិយម ( Antimaclinisme ) ។ លោកចូលចិត្តធ្វើដំណើរដោយជើង ព្រោះលោកយល់ថា ÷

« សេចក្ដីល្អធ្វើដំណើរយឺត, ដូចអណ្ដើកវារ » សេចក្ដីល្អមិនត្រូវការប្រញាប់ប្រញាល់ពេកទេ គេដឹងថាបើនិងពន្យល់មនុស្សអោយធ្វើល្អត្រូវប្រើពេលយូរងចំណែក, សេចក្ដីអាក្រក់វិញមានស្លាបហើរបាន» ដើម្បីសង់ផ្ទះគេត្រូវប្រើពេលវេលាយូរ តែគេរុះរើផ្ទះដោយរយៈពេលយ៉ាងឆាប់ រដ្ឋការអង់គ្លេសពុំមានមនោសញ្ចេតនា ទោរទន់អាណិតអាសូរចំពោះបាតុករទាំងឡាយនោះទេ តែវាខឹងនឹងបាតុករនាំគ្នាឈប់ធ្វើការប៉ុណ្ណោះឯង ។ ហឹង្សាកិច្ចរបស់អង់គ្លេសពុំសម្រេចក៏ចាប់ឃុំឃាំងរូបមហាត្មៈគន្ធី ដើម្បីបង្ខំអោយបាតុករបញ្ឈប់សកម្មភាព ។ ក្រោយមកសកម្មភាពត្រូវធូរស្រាលឡើងវិញ ព្រោះចក្រពត្របានលែងមហាត្មៈអោយមានសេរីភាព តែគេហាមពុំអោយលោកចូលទៅខែត្របញ្ជីមឡើយ ។ មហាត្មៈយល់ថាត្រូវតែនៅស្ងៀមស្ងាត់ ព្រោះ

ថា ពិតមែនតែមានភ្លើងរោលរាល សព្វសព៌ាង្គកាយរបស់លោក ហើយឆេះជុំវិញខ្លួនលោកក៏ដោយ បើឱកាសពុំទាន់ហុចអោយទេ គេត្រូវប្រើធមិខន្តី ដើម្បីរង់ចាំនៅថ្ងៃក្រោយ ។ មហាត្មគន្ធីជាអ្នកនយោបាយផង ជាទស្សនវិទូផង ព្រោះថាលំនៅរបស់លោកមានតែពីរគឺអាស្រមបទនិងគុក ។

សាវ័កដែលលោកស្រឡាញ់ទុកចិត្តជាងគេ គឺ ទស្សនវិទូសុភាចន្ទ្រ បុស្ស មេនយោបាយរដ្ឋបឹងកាល់ ។ មហាត្មៈលោក «ឈរ៍ហាឌីន» ប្រមុខសហគមន៍គំម៉ែងវាលបានជូនមេដៃមាសដល់លោក។

តែអំពើល្អពុំមែនបានន័យថា ខ្វះបច្ចាមិត្រឡើយ ។ មហាត្មៈទៅជាឧបករណ៍ នៃការច្រណែនរវាងបញ្ញាវ័ន្តឥណ្ឌា នៅអាហ្វ្រិកខាងត្បូង ហើយបានទទួលទារុណកម្ម និងជាប់គុកព្រោះចិត្តសន្ដោស និងសច្ចៈភាព ។ ,

នៅក្នុងពន្ធនាគារ, មហាត្មៈគន្ធីតែងទន្ទេញភាសិតរបស់អ្នកប្រាជ្ញជាតិរុស្ស៊ីឈ្មោះ តុលស្តយ ( TOLSTOI ) ថា ÷

«ព្រះជាណាចក្ររបស់ព្រះអាទិទេពនៅក្នុងចិត្តរបស់អ្នកឯង»

ក្រោមទម្ងន់ដំបងដែលគេវាយមកលើខ្លួនលោកម្តងៗ មហាបុរសតែងពោលថា ÷

« ព្រហ្មវិហារធម៌ គ្មានព្រំដែនទេ » ។

ពេលចេញពីគុកមហាត្មៈ បានបោះបង់ចោលនូវវិជ្ជាជីវៈ ហើយបានចូលទៅកាន់គេនជាឫស្សី ។ សកម្មភាពមហាត្ម ត្រជាក់ជាងវារីនេះទៅទៀត ។ ឯសត្វសាហាវមាន ខ្លា, ដំរី, ជ្រូកព្រៃ ។ សឹងតែគេចវេះចុះទៅរស់នៅតាមទីវាល អាហេទូពីទទាំងអសទុកឱកាសអោយអាញ្ញី, អែអូដ, ព្លេះ, ប្រើស, រមាំង, ក្តាន់បណ្តើរកូនយ៉ាងសប្បាយ ។ ក្រៅពីនេះបក្សាបក្សីសកុណីជាច្រើនបានមកភាច់សំបុកទុកកូនតាមចន្លោះវល្លិ៍ដែលដុះរយោនរយានធ្លាក់ចុះមកពីមែកឈើ ។

យើងឃើញថាមហាត្មស្រឡាញ់ និងចូលចិត្តរស់នៅក្នុងធម្មជាតិស្ងប់ស្ងាត់ដូចទស្សនវិទូរូស្សូ ( J. Rousseau ) ដែរ ។ តែផ្ទុយទៅវិញ លោកពុំបានស្អប់សង្គមមនុស្សរហូតដល់ទៅបោះបង់ចោល ឬដាក់កំហុសទៅលើសង្គមនោះខ្លាំងពេកទេ ។ លោកគន្ធីស្រឡាញ់ពាក្យសច្ចៈជាងជីវិត ហើយលោកមិនដែលពោលពាក្យកុហកទេ ។

លោក រ៉ាយ ប៊ិក បានពោលថា :

«មហាត្មគន្ធីភ្ញាក់ពីនិទ្រាវេលាម៉ោង ៤ កន្លះ រួចល្ងាចថ្វាយបង្គំព្រះ សូត្រធម៌ហើយទើបលោកដើរ ។ តរយាបទឥណ្ឌាវិញ ដោយបំពាក់មកជាមួយនូវកម្រងកិត្យានុភាពដ៏មហាស្ចារ្យផង ។

ចូលមកដល់មាតុប្រទេសវិញ លោកមើលឃើញនឹមដែក ដែលអង់គ្លេសសង្កត់លើប្រជាជនឥណ្ឌាជាច្រើនឆ្នាំមកហើយនោះ ត្រូវក្រុមអ្នកស្នេហាជាតិឥណ្ឌាជាច្រើនក្រុម កំពុងរៀបគ្រោងការបដិវត្តន៍ ដោយឆ្លៀតឱកាសប្រទេសអង់គ្លេសកំពុងជាប់ដៃធ្វើសង្គ្រាម ។ ពេលនោះប្រជាជនឥណ្ឌាចំនួន ១៨៥.០០០នាក់ ត្រូវអង់គ្លេសកេណ្ឌអោយទៅធ្វើទាហាន ។ មហាត្មាក៏ពុំបានចូលរួមក្នុងអង្គការរំដោះណាមួយឡើយ តែផ្ទុយទៅវិញ លោកបានធ្វើដំណើរទៅប្រទេសអង់គ្លេស ដើម្បីនិងតាំងនូវនិងក្រុមរក្សារបួសឥណ្ឌា ហើយព្រួតដៃជួយប្រទេសអង់គ្លេសក្នុងសង្គ្រាមនោះដោយពេញដៃ ។

សង្គ្រាមអង់គ្លេសផុតរលត់ ដោយនាំមរណៈភាពមកអោយប្រជារាស្ត្រឥណ្ឌាចំនួន ១៨៥.០០០នាក់ផង ។ មហាត្មាបានត្រឡប់មកឥណ្ឌា ដោយទទួលការពេញចិត្តពីអ្នកកាន់អំណាចអង់គ្លេសជាពន់ពេក តែអកុសលរាស្ត្រឥណ្ឌាប្រកបដោយសញ្ជាតិ និងសាសនាប្លែកគ្នាជាច្រើន មានទំនាស់រវាងសាសនាមហាត្មា និងសាសនាហិណ្ឌូ ។ សភាពច្របូកច្របល់គឺពួកឥណ្ឌា ពុំព្រមទទួលស្គាល់ពួកមហាមត់អោយរស់នៅក្នុងទឹកដីឥណ្ឌា ម្យ៉ាងទៀតពួកមហារាជាដែលធ្លាប់កាន់កាប់អំណាចជាច្រើនសតវត្សមកហើយនោះ ក៏បំផុសនូវទំនាស់ក្នុង

ស្រុក បណ្តាលអោយរដ្ឋាភិបាលអង់គ្លេសក្រាញ់ និងអំណាចហើយ ទាត់ចោលគុណសម្បត្តិ និងសំណូមពររបស់មហាត្មគន្ធី ។ មហាត្មគន្ធី បានប្រកាសអោយប្រជារាស្ត្រអត់អាហារ ហើយសូត្រធម៌រវាងមួយថ្ងៃ ដែលបានទទួលនៅជោគជ័យយ៉ាងធំ ពីព្រោះប្រជាជនចំនួនមួយលាន អ្នកផ្តើមអត់អាហារតាមមហាត្មៈគន្ធី ។ ពេលនោះច្បាប់អាជ្ញាសិកបាន ចាប់ប្រជាជនដែលនាំគ្នាអត់អាហារនោះទៅព្ឋរកយ៉ាងច្រើន ដើម្បី ទប់ទល់និងសកម្មភាពនេះ ។ រដ្ឋការអង់គ្លេសពុំមានមនោសញ្ចេតនា ទោរទន់អាណិតអាសូរចំពោះបាតុករទាំងឡាយនោះទេ តែវាខឹងនឹង បាតុករនាំគ្នាឈប់ធ្វើការប៉ុណ្ណោះឯង ។ ហិង្សាកិច្ចរបស់អង់គ្លេសពុំ សម្រេចក៏ចាប់ឃុំឃាំងរូបមហាត្មគន្ធី ដើម្បីបង្ខំអោយបាតុករបញ្ឈប់ សកម្មភាព ។ ក្រោយមកសកម្មភាពត្រូវធូរស្រាលឡើងវិញ ព្រោះចក្រ ពត្របានលែងមហាត្មៈអោយមានសេរីភាព តែគេហាមពុំអោយលោក ចូលទៅខែត្របញ្ចឹមឡើយ ។ មហាត្មយល់ថា ត្រូវតែនៅស្ងៀមស្ងាត់ ព្រោះថាពិតមែនតែមានភ្លើងរោលរាល សព្វសព៌ាង្គរបស់លោក ហើយឆេះជុំវិញខ្លួនលោកក៏ដោយ បើឱកាសពុំទាន់ហុចអោយទេ គេ ត្រូវប្រើធមិខន្តី ដើម្បីរងចាំនៅថ្ងៃក្រោយ ។ មហាត្មគន្ធីជាអ្នក នយោបាយផង ជាទស្សនវិទូផង ព្រោះថាលំនៅរបស់លោកមានតែពីរ គឺអាស្រមបទ និងគុក ។

សាវ័កដែលលោកស្រឡាញ់ទុកចិត្តជាងគេ គឺទស្សនវិទូ សុភាចន្រ្ទបុស្ស មេនយោបាយរដ្ឋបឹងកាល់ ។ ថ្ងៃ ៨ សីហា ១៩៤៧ ក្រោយសង្គ្រាមលោកលើកទី ២ ប្រទេសឥណ្ឌាបានជារួចជា ប៉ុន្តែផែនដីនេះត្រូវគេពុះចែកជាពីរគឺ បាគីស្ថង់, និងឥណ្ឌូស្ថង់ ហើយដែលសព្វថ្ងៃនេះ យើងឃើញមានបាគីស្ថង់ កើតមានថ្មីមួយទៀតអមសងខាងប្រទេសឥណ្ឌាបច្ចុប្បន្ន ។

តាំងពីរនោះមក មហាត្មៈគន្ធី ត្រូវប្រជារាស្ត្រចាត់ទុកជា បិតានៃរដ្ឋឥណ្ឌា ដែលមានលោកនេហ៍រូជានាយករដ្ឋមន្ត្រី ។

មហាត្មជាកំពូលមនុស្ស ដែលអាចណែនាំប្រជាជនអោយយល់ហើយធ្វើតាម និងប្រតិបត្តិតាមឧត្តមគតិរបស់លោក ។

លោកតែងពោលថា ÷

«ចូរប្រជាជនឥណ្ឌាទាំងឡាយ ប្រើគេសំពត់អំបោះត្បាញ នៅគ្រឹហាររបស់ខ្លួន»

«ត្រូវព្យាយាមយកអំបិលពីទឹកសមុទ្រ ដោយខ្លួនឯងដើម្បីជៀសវាងនូវការបង់ពន្ធអំបិល»

សូមជ្រាបថា អង់គ្លេស ចម្រាញ់យកវត្ថុធាតុដើមរបស់ឥណ្ឌា មានក្រូបាស អំបិល ។ល។ ទៅផលិតនៅស្រុកខ្លួនដោយប្រើម៉ាស៊ីន ហើយយកកំណាត់សំពត់ ឬវត្ថុធាតុផលិតដោយម៉ាស៊ីនមកលក់ម្ចាស់ស្រុកវិញ ដោយមានតម្លៃ ១ ជា ១០០ ដូចកាលអាណានិគមនបារាំងវាធ្វើចំពោះប្រទេសខ្មែរយើងដូច្នោះដែរ ៕

# មហាត្មៈគន្ធី ប្រើអហិង្សាតទល់ និងពួកយោគីឥណ្ឌា

លោក រ៉ឺណេដឺបែរវ៉ាស់ ( RENE de BERVAL ) បាន ពោលថា «នៅក្នុងសង្គមឥណ្ឌា, ការស្វែងរកទីផុតទុក្ខ, ដែលមនុស្ស ឥណ្ឌាគ្រប់វណ្ណៈចាប់រាប់តាំងពីវណ្ណៈក្សត្រ រហូតដល់វណ្ណៈចណ្ឌាល័ត ពួក ( SUDRA ) នាំគ្នាអនុវត្តនោះ មានលក្ខណៈផ្សេងៗគ្នា ។

លោក «រ៉ឺណេដឺបែរវ៉ាល់» បានពោលថែមទៀតថា ÷

«ក្នុងមួយឆ្នាំម្តងៗនៅទីក្រុង បេណារ៉េសនៃប្រទេសឥណ្ឌា គេសង្កេតឃើញមានមនុស្សរាប់រយម៉ឺននាក់ បានធ្វើដំណើរចាកចោល ភូមិស្រុករបស់ខ្លួន ដើម្បីមកកាន់មាត់ទន្លេគង្គា ( GANGA ) ។ ហើយនៅទីនោះ គេបាននាំគ្នាប្រារព្ធពិធីមុជទឹកលាងបាប ។ គេបាន នាំគ្នាបោះជំរំជាខ្ទម ឬជម្រកដែលមានតែដំបូលប្រក់ពីលើបន្តិចបន្តួច ប៉ុណ្ណោះ ។

លោកបែរវ៉ាល់បន្ថែមទៀតថា ÷

«ទីនោះជាពិភពអស្ចារ្យ ដែលភ្ញៀវទេសចរណ៍ទាំងឡាយតែង

បានជួបប្រទះ នូវទស្សនីយភាពប្លែករាប់ពុំអស់ឡើយ ។ គឺថារីភាពភាព ដែលគួរពិចពិលរមិលមើល ហើយព្រមជាមួយគ្នានោះ គេបានប្រទះ ឃើញនូវផ្លូវទស្សនរបស់មនុស្ស ដែលបាននាំគ្នាផ្ញើព្រលឹងជីវិតរបស់ ខ្លួនគេម្នាក់ៗអោយព្រះអាទិទេពទុកអោយ ។ គឺជារូបារម្មណ៍នៃមនោ សញ្ចេតនា របស់មនុស្សលោក ដែលនាំគ្នាទាមទារ អោយព្រះជាម្ចាស់ ត្រួសត្រាយដឹកនាំមាគ៌ាយផុតទុក្ខដល់គេ ។ នៅមាត់ទន្លេគង្គា ប្រជាជនឥណ្ឌា ដែលមានជំនឿយ៉ាងជាក់ស្តែង ទៅតាមគម្ពីរផ្សេងៗ បូរាណ, គម្ពីររបស់សាសនាខ្លួនដូចជាគម្ពីរ៉ក្រវេទ គម្ពីរវិស្ណុបូរាណ, ឬសីវបូរាណ ក៏តែងសង្ឃឹមទុកនៅក្នុងអារម្មណ៍ចិត្តរបស់គេម្នាក់ថា :

«ឱព្រះម៉ែគង្គាដ៏ប្រសើរអើយ ! យើងខ្ញុំរស់នៅមានជីវិតរហូតមកដល់ ពេលនេះ ក៏អាស្រ័យទឹកសុជនរបស់ព្រះម៉ែដែរ ទឹកសុជននេះជាទឹក អម្រិតដែលកើតឡើងពីការបូជារបស់ពពួកទេពនិករ និងពួកអសុរ, សូមព្រះម៉ែចែករំលែកទឹកអម្រិតលាងសំអាតរាងកាយ និងចិត្តយើង ខ្ញុំទាំងអស់គ្នា ដែលជាប់នៅក្នុងទ្រូងនៃកាល ( KALA ) នេះផង ចុះ ! » គេម្នាក់ៗតែងស្វូត្រពុំដាច់ពីមាត់នូវពាក្យអង្វរករនេះ ចំពោះ ទន្លេគង្គា ។ លោកបែរវាល់ពោលថា÷

«ទិដ្ឋភាពដែលគួរអោយយើងចាប់អារម្មណ៍ជាងគេ គឺពួកមហាឫស្សី យោគីនឥណ្ឌា ដែលមានខ្លះលះបង់សំលៀកបំពាក់ របស់ខ្លួនស្ទើរតែ

ទាំងអស់ ហើយអញ្ចាលីផ្គុំឡើង នេត្រាបិត» ឈរបែរមុខទៅរក ព្រះអាទិត្យ ហើយសូត្រធមិតាមតម្ពីរសាសនារបស់ខ្លួន ដែលមានរយៈ ពេលយ៉ាងយូរ ពុំចេះអស់សោះ ។ មានអ្នកខ្លះអង្គុយធ្វើយោគពិធីមាន ពែនភ្នែន ធ្វើដំណើរដង្ហើបអោយស្មើរវាងអស្សាសៈប្បស្សាៈ ជូនគេ សណ្តូកដៃឆ្វេងទៅលើ បាតជើងទាំងពីរដែលគេបានកាច់ពត់មកលើ ជង្គង់ ហើយលើកដៃស្តាំរាបែប «អភ័យមុទ្រ ( ABHAYA MUDRA )។ មានខ្លះឈរលើកដៃទាំងពីរឡើងលើ ពុំបរិភោគអាហារ ទាំងយប់ទាំងថ្ងៃ រហូតហេវហត់អស់កម្លាំងរលំខ្លួនដួលដេកទៅលើ ផែនដី ទាល់តែមានពេទ្យអ្នសយកទៅព្យាបាល ។ មានពួកយោគិន មួយពួកទៀត ទុកសក់វែងរហូតដល់ចង្កេះ រួចទើបគេពត់ជើងគេទាំង ពីរអោយផ្តក់មកលើក ទើបយកសក់ចងជើង ដែលគេបត់ខ្វែងពីខាង មុខ ។ ដៃគេទាំងពីររបត់ផ្ទោបមកសំពះនៅពីមុខ ។ យោគពិធីនេះត្រូវ ពពួកមហាបូស្សីយោគិនទាំងឡាយយកមកអនុវត្ត ក្រោយពីមុជទឹក លាងបាបរួចហើយ ។

ក្រៅពីនេះ មានពួកអាកែលជាច្រើន ដែលនាំគ្នាកាន់សាសនា ព្រះឥសូរ ( SIVA ), បានយកដេះមកប្រឡាក់សារពាង្គកាយដែលបិត បាំងដោយបន្ទះកំណាត់សំពត់ ទុកតែកេរ្តិ៍ខ្មាស់បន្តិតប៉ុណ្ណោះ ។

មនុស្សមីដេរដាស កកស្រទាប់នៅតាមមាត់ទន្លេតង្ការហូតមកដល់ផ្លូវធ្វើចរាចរ ។ មានពួកអាយលម្ពាយតម្រោបកន្ត្រកស្មុករបស់ខ្លួនពីមុខ ហើយបើកគម្របកន្ត្រកទុកអោយសត្វពស់វែកងើបមកបើកពពារបញ្ចេញអណ្តាតភ្លែម ។ ហើយយោលខ្លួនងឹកងោកតាមចង្វាក់ប៉ីដែលម្ចាស់វាផ្លុំអោយវារាំ ។ ក្រៅពីនេះមានពួកស្ងួមក្មេងចាស់ស្រីប្រុស រត់ប្រសាចស្រែករត់តាមសុំទានទេសចរណ៍ ដែលចូលទៅដល់នៅទីនោះ ។ ទិដ្ឋភាពទាំងអស់នោះបានធ្វើអោយមតិពិភពលោកដែលមានសញ្ជាតិ និងសាសនា ខុសពីឥណ្ឌាមានសេចក្តីស្តាយចំពោះសម្បជញ្ញៈ នៃមនុស្សជាតិទាំងឡាយនោះដែលបណ្តោយអោយសាសនាឃុំទុកស្មារតីនៃជើងមេឃឥណ្ឌា អោយយល់នូវស្រមោលនៃចង្វាក់ពេលវេលា វឌ្ឍនធម៌ដ៏រុងរោចន៍របស់វិទ្យាសាស្ត្រ និងការរស់នៅយ៉ាងសប្បាយរបស់មនុស្សដូចគ្នាបាន ។ រឿងពួកយោគីនឥណ្ឌាមានទាក់ទងនិងទស្សនវិជ្ជា របស់មហាត្មៈគន្ធីដែលយើងសូមដកស្រង់ដូចតទៅ ។

លោក រ៉ូ ណេដឺបែវាល់ បានពោលបញ្ជាក់ប្រាប់យើងថា :

«កាលនោះមហាត្មៈគន្ធីនៅជានិស្សិតនៅឡើយ ថ្ងៃមួយមិត្ត-

ភ័ក្រលោកច្រើន នៅសាកលវិទ្យាល័យនាក្រុង «បិហារ» បានបបួលយុវនិស្សិតគន្ធី អោយចូលរួមក្នុងពិធីមុជទឹកលាងបាបនៅទីក្រុងបេណារ៉េស ។ និស្សិតគន្ធីរញ្ជរាក្នុងចិត្តក្រៃ លែងចំពោះការបបួលដែលមិត្តភ័ក្រទាំងឡាយរបស់លោក បានចាប់អារម្មណ៍ដល់លោក ។ លោកបានដឹងថាគេទាំងឡាយចង់ពិសោធចំពោះទឹកចិត្តលោកកាលពីថ្ងៃមុន ដែលបានប្រឆាំងយ៉ាងខ្លាំងក្លាបំផុត និងទ្រឹស្តីសាមាវេទ ( SAMA VEDA ) ។

លោកពុំបានដាក់កំហុសទៅលើគម្ពីរវេទ របស់ឥណ្ឌាសម័យនោះទេ តែលោកយល់និងការអនុវត្តន៍នូវធម៌ដែលពពួកអ្នកកាន់សាសនាសម័យនោះយល់ច្រឡំ ។ លោកគន្ធីបានប្រកាសជាសាកលនៅចំពោះមុខ សភានិស្សិត និងព្រឹទ្ធិសាស្ត្រាចារ្យទាំងអស់ដែរ បានមកប្រមូលផ្តុំនៅក្នុងទីលានសាកលវិទ្យាល័យលោកថា ÷

«គោលដៅរបស់អ្នកកាន់សាសនានាយោគ ( YOGA ) ចេះតែជម្រុញជំនឿរបស់ខ្លួន អោយរិតតែផុងចូលទៅក្នុងការភ័នច្រឡំតែខ្លាំងឡើងៗ ការធ្វើអត្តវិប្បយោគរបស់មហាឫស្សី បើគ្រាន់តែអនុវត្តទៅតាមគម្ពីរឫកវេទ ( REGVEDA ) ឬសមាវេទ ( SAMAVEDA) ប៉ុណ្ណោះឃើញថា ជាការបន្ទាប់បន្ទំទេ ក៏ប៉ុន្តែការធ្វើទុក្ខរកម្ម ដែល

មហាឫស្សីយោគីនទាំងនោះបានចាប់ផ្ដើមគរហើយៗ ជាអំពើដែលពុំគ្រាន់តែឃ្លាតឆ្ងាយពីគោលដៅសាសនាប៉ុណ្ណោះទេ តែការនេះមានលក្ខណៈរឹតតែប្លែក ហើយសាហាវណាស់ រាងកាយដែលគេជឿថាព្រះប្រាជាបតិ ( PRAJAPATI ) បង្កើតមក ។ លោកគន្ធីបានឆ្លើយចំពោះសំនួរសាស្ត្រាចារ្យលោកដែលបានសួរលោកថា «តើភ្លើងដែលបានដុតរាងកាយមនុស្សអោយក្ដៅក្រហាយ ហើយនិងភ្លើង ដែលដុតពិភពលោកអោយរលាយទៅជាផេះនោះ គេអាចចាត់ទុកថាជាអំពើរបស់ព្រះសិវបានដែរឬអ្វី ? »

លោកគន្ធីបានឆ្លើយថា «បើព្រះសិវជាអ្នកបង្កើតភ្លើងទាំងពីរនេះ មានតែព្រះសិវខ្លួនឯងប៉ុណ្ណោះទេដែលអាចរំលាយបាន» ។

ពេលនោះសាស្ត្រាចារ្យមហាបណ្ឌិតម្នាក់ បានសួរលោកថា ÷

«ព្រោះតែចង់រំលត់ភ្លើងដែលឆេះនៅក្នុងអារម្មណ៍ និងកាយនេះហើយ ដែលពួកមហាឫស្សីយោគីន ខំនាំគ្នាធ្វើសមាធិ, ហើយព្រមទាំងបានធ្វើទារុណកម្មខ្លួនឯងអោយដល់នូវសេចក្ដីទុក្ខយ៉ាងខ្លាំង ដើម្បីធ្វើអោយព្រះសិវទ្រង់ចុះមកជួយពន្លត់ភ្លើងនោះ តើពួកមហាឫស្សីធ្វើនេះពុំមែនជាមាគ៌ាដែលគម្ពីរវេទបានចង្អុលបង្ហាញទេឬអ្វី ?

លោកគន្ធីបានឆ្លើយថា ÷

«គម្ពីរវេទពុំបានប្រាប់ថា ព្រះសិវទ្រង់គង់នៅទីណាឡើយ ។ តែបើថាព្រះសិវគង់នៅភ្នំកៃលាស ឬភ្នំព្រះសុមេរុ ( MERU ) ឬក៏ថាលើកំពូលភ្នំមន្ទរៈ ក៏យើងដើររទៅរកព្រះសិវពុំឃើញដែរ ។ តែបើឧបមាថា រកទ្រង់ឃើញក៏យើងពុំអាចយកជាការបានដែរ ព្រោះថាមធ្យោបាយភ្លើងពន្លត់ភ្លើងជានាទីរបស់ព្រះអាទិទេពប៉ុណ្ណោះ ពុំមែនជាមធ្យោបាយរបស់មនុស្សលោកទេ» ។

ពេលនោះគេនាំគ្នា ចម្លែកនិងនិស្សិតគន្ធីដែលហ៊ានពោលដោះស្រាយគម្ពីរវេទ ហើយព្រមទាំងហ៊ានធ្វើការនិទាន ចំពោះមហាឫស្សីយោគិនថែមទៀតផង ។ មិត្តភ័ក្រលោកគន្ធីយល់ថា ការប្រឡងរបស់មហាត្មៈនៅពេលបំណាច់ឆ្នាំខាងមុខនេះ ច្បាស់ជាពុំបានទទួលជោគជ័យឡើយ ព្រោះថាលោកបានប្រឆាំង និងឆន្ទៈសាសនាដែលគ្រូរបស់លោកគោរពបូជា ។

សមាជនិស្សិតស្តីពីបញ្ហាសាសនាក្នុងឱកាសនោះ បានត្រូវរកជ្រើសរើសមហាត្មៈគន្ធី អោយធ្វើជាប្រធានខាងប្រឆាំង ឯចំណែកខាងក្រុមការពារ ត្រូវបានទៅលើសាស្ត្រាចារ្យម្នាក់ចាស់ជាងគេឈ្មោះ « កុមារានន្ទ » ដែលត្រូវជាគ្រូម្នាក់របស់មហាត្មៈគន្ធីដែរ ។

សូមជំរាបថាលោក នន្ទ ស្រឡាញ់មហាត្មៈគន្ធីណាស់ ថ្វីត្បិត

តែលោកត្រូវគេចាត់តាំងអោយធ្វើជាអ្នកការពារគម្ពីរវេទ ក៏លោកពុំបានបដិសេធ នូវឆន្ទៈរបស់សិស្សលោកម្នាក់នេះឡើយ ។

លោកគន្ធីបានគិតទុកជាស្រេចថា ទស្សនមហាត្មៈគន្ធីជាទស្សនរបស់ព្រះពុទ្ធសាសនា ពុំមែនជាមាតិរបស់ជនសាសនាឡើយ ហើយឆន្ទៈនេះជាដើមកំណើតរបស់ទស្សនវិជ្ជាមួយនិយមយក ប្រភពរូបមន្តពីរគន្ធីមក្នាមកធ្វើជានិមិត្តរូប ឬឧទាហរណ៍ក្នុងការពិសោធន៍ រាវរកតម្លៃផ្សេងៗក្នុងអាកាសអាថិកំបាំង ។ គឺជារូបមន្តមានគូ ( La dualisme de Gandhi ) ដែលកាន់ដៃគ្នាស្វែងរកភពអាថិកំបាំង ។

ហេតុដូច្នេះហើយបានជាលោកសាស្ត្រាចារ្យកុមារានន្ទី សូមអោយមិត្រភ័ក្រទាំងអស់ អញ្ជើញលោកគន្ធីទៅរាវរកការពិតក្នុងលំនៅគុហររបស់ពួកមហាឫស្សីនៅបេណារ៉េស ។

លោក រ៉ុណេឌីបែរវ៉ាល់ បានបញ្ជាក់ថា មហាត្មៈយល់ស្រប តាមសេចក្តីអញ្ជើញរបស់មិត្តភ័ក្រលោក និងគ្រូលោក ។

មហាត្មៈក៏បានធ្វើដំណើរទៅកាន់ក្រុង បេណារ៉េស ដែលនៅទីនោះ លោកបានទទួលការជប់លៀងយ៉ាងធំនៅផ្ទះលោកសាស្ត្រាចារ្យ កុមារានន្ទី ។

សាស្ត្រាចារ្យនន្ទី មានសេចក្តីត្រេកអរជាពន្លឹក ដោយឃើញ

មហាត្មៈធ្វើដំណើរមកមេណាវ៉ាស៊ី តាមចេតនាក្តីអញ្ជើញរបស់ខ្លួន ។ ពេលនោះ លោកបានបង្ហាញរូបមហាត្មៈអោយសមាជិកក្នុងគ្រួសារលោកស្គាល់គ្រប់គ្នា ព្រមទាំងចាត់អោយគេទៅអញ្ជើញបងបង្កើតរបស់លោក ពីគុហាពួកយោគ្គិនមកចូលរួមនៅពេលលាងសាយភោជន៍នោះដែរ ។

សូមជំរាបថា មហាឫស្សីយោគ្គិនពុំមែនសុទ្ធតែជាអ្នកក្រកំសត់ទុរគតទេ, ក៏ប៉ុន្តែគេឃើញអ្នកមានស្តុកស្តម្ភដែលជុះជំនឿនេះក្នុងអារម្មណ៍ចិត្តរបស់ខ្លួននោះ បានសុខចិត្តបង់ទ្រព្យសម្បត្តិ និងកេរ្តិ៍មតិកខ្លួន ហើយធ្វើដំណើរទៅកាន់វិថីរលត់ទុក្ខតាមបែបយោគ្គា ( YOGA )។ ឧទាហរណ៍ដូចជាបងបង្កើតរបស់លោកសាស្ត្រាចារ្យកុមារានន្ទីនេះជាភស្តុតាងស្រាប់ ។

ក្រោយដែលជប់លៀងភោជន៍នាហារ រួចហើយមានការចរចាប្តូរយោបល់រវាងនិស្សិតមហាវិទ្យាល័យរដ្ឋប៊ីហារ ដែលមានមហាត្មៈគន្ធីជាប្រធាន និងមហាឫស្សីយោគ្គិនបងរបស់លោកសាស្ត្រាចារ្យកុមារានន្ទី ជាអ្នកឆ្លើយ ។ ហើយការចចារនេះ លោកអ្នកនិពន្ធ រ៉ុណោជីបែរវ៉ាល់ ចាត់ទុកជាជាទស្សនវិជ្ជាផ្នែកចរិយាសាស្ត្រ ដែលមានមូលដ្ឋានស្វែងរកការពិត. សច្ចៈភាពតាមរយៈទស្សនវិជ្ជាត្រជាក់ ដែល

គេច្រើនអោយឈ្មោះថា **ឧសុ្សនទិដ្ឋារអហិង្សា** ( AHIMSA ) ។

មហាត្ថះគន្ធីសួរមហាបូស្សិរយាគ្គិនថា ÷

«តើតេត្រូវមានលក្ខណៈប៉ុន្មានយ៉ាង ដើម្បីធ្វើខ្លួនអោយទៅអ្នកយោគិ្គនម្នាក់ដ៏ប្រសើរ ? »

មហាបូស្សិឆ្លើយថា ÷

«ពុំបាច់មានលក្ខណៈ អ្វីពិសេសពិសាលប៉ុន្មានឡើយ បើមនុស្សសាមញ្ញម្នាក់ចង់ធ្វើខ្លួនអោយទៅជាអ្នកប្រព្រឹត្តយោគ្គិន ក៏ប៉ុន្តែជាពិសេស អ្នកចង់ធ្វើយោគ្គិនត្រូវសុំសេចក្ដីអនុញ្ញាតពីចិត្តរបស់ខ្លួនជាមុនសិន »

មហាត្មះគន្ធីសួរទៀតថា ÷

«តើគម្ពីរ, អ្វីខ្លះដែលយោគ្គិនយល់ថាជាក្បួនច្បាប់ត្រឹមត្រូវសម្រាប់រៀនយោគ ? »

«ក្បួនដែលអ្នកប្រតិបត្តិតួរយកធ្វើជាគ្រឿងបំភ្លឺខ្លះនោះ គឺគម្ពីវេទទាំងអស់ តែគេអាចសិក្សាតែមួយក៏បានគឺ សម្រាប់សូត្រភាវនាក្នុងពេលធ្វើពិធីសម្មាធិកម្ម ឯចំណែកក្បួនអគ្គីបុរាណ ( AGNIPU-

RANA ) ឬសីវបុរាណ ( CIVA-PURANA ) អ្នកប្រតិបត្តិយោគត្រូវដឹងរឿង ហើយស្គាល់ប្រវត្តិខ្លះៗរបស់ព្រះប៉ុណ្ណោះ» (មហាឫស្សីឆ្លើយ)

មហាត្មៈសួរបន្ថែមទៀតថា ÷

«តើនរណា ជាគ្រូដំបូងបង្អស់របស់ពួកយោគិន ? »

មហាឫស្សីឆ្លើយថា ÷

«ព្រះសីវ ព្រះអង្គលះបង់រាងកាយហើយស្អប់រាងកាយ ទ្រង់ស្លៀកស្បែកខ្លាទុកខ្លួនទទេ គង់លើផ្កាឈូកព្រះហស្តកាន់លំពែងត្រីសូរ ( TRIDENT ) ដែលគេសង្កេតឃើញព្យួរនៅកលំពែង ពិងពាងមួយតូច ស្គរតូចនេះជារកាំងរោទិ៍រណ្តំ ដាសវិញ្ញាណប្រស់ ព្រលឹងសត្តនិតរអោយរស់ឡើងវិញ ។ តែកុំភ្លេចថាទ្រង់ជាអ្នកដុតបំផ្លាញចោលអ្វីៗ ទាំងអស់ដោយត្រីនេត្រ ស្ថិតនៅពួជថ្ងាសនោះវិញ ។

មហាត្មៈបញ្ជាក់ថា ÷

«បើសិនសិរីរាងកាយរបស់ព្រះសីវៈជាអគ្គិ តើទ្រង់ត្រូវការអ្វីដើម្បីពន្លត់អគ្គិ ? »

មហាឫស្សីឆ្លើថា ÷

« គេពុំយកទឹកវិលត់ព្រះអគ្គិ ព្រះសិវៈទេ »

« តែគេយកភ្លើងវិលត់ »

មហាត្មបន្ថែមថា ÷

- ដូច្នេះបានសេចក្ដីថា ÷

« ភ្លើងវិលត់ភ្លើង ទឹកវិលត់ទឹកឬ ? »

- ពិតមែន ! ( មហាឫស្សីឆ្លើយ )

មហាត្មយល់ថាយោគីនកំពុងចូលទៅក្នុងសំណាញ់ នៃការចេះដឹងហើយក៏បន្ថែមថា ÷

«ចុះចិត្តរបស់ខ្ញុំដែលប្រកបដោយភ្លើង តើខ្ញុំត្រូវយកអ្វីទៅលត់ ? »

មហាឫស្សីឆ្លើយថា ÷

ត្រូវយកចិត្តទៅវិលត់ចិត្ត «តែចិត្តកំហឹងរបស់អ្នកឯង ពុំអាចយកភ្លើងកំហឹងទៅវិលត់ចិត្តខឹងបានទេ !

មហាត្មៈបញ្ជាក់ :

«ដូច្នេះចិត្តភ្លើងពុំអាចវិលត់ដោយចិត្តភ្លេងបានទេ តែគេយក

ចិត្តទឹកទៅរំលត់ចិត្តភ្លើង ?

- ពិតមែន ! (មហាឫស្សីឆ្លើយ) ពេលនោះមហាត្មៈចាប់អោយយោបល់ថា ÷

យើងឃើញហើយថា ចិត្តទឹកអាចរំលត់ចិត្តភ្លើង ! ។ មានតែការអត់សង្កត់ចិត្តទ្រាំទ្រ ប្រើអហិង្សាប៉ុណ្ណោះទេ ដែលមនុស្សអាចអនុវត្តអ្វីទាំងឡាយបាន ! ព្រះកាយរបស់ព្រះសិវជាភ្លើង ព្រោះទ្រង់ជាភ្លើងដែលយើងបានឃើញនឹងភ្នែកស្រាប់ហើយ នៅក្នុងគម្ពីរអគ្គីបុរាណ ។ ទ្រង់តែងយកផេះមកលាបរាងកាយរបស់ព្រះអង្គ ដើម្បីបង្ហាញអោយអ្នកទាំងឡាយយល់ថា កាលវេលាមកដល់ហើយ រាងកាយនេះឯងនឹងទៅជាផេះ ។ តែផេះរបស់ព្រះអង្គខុសនឹងផេះរបស់យើង ដែលកើតមកពីកំទេចធ្យូងក្រខ្វក់ ។

ផេះរបស់ព្រះអង្គជាផេះពុំប្រឡាក់ដៃ ហើយព្រះនេត្ររបស់ព្រះអង្គមានខុសនឹងភ្នែកយើងគ្រប់គ្នា ព្រះនេត្រនៅលើថ្ងាសកើតឡើងភ្លាម ប្រកបដោយគុណវិបត្តិរាប់ពុំអស់ គឺទ្រង់បង្កើតឡើងសម្រាប់បំផ្លាញព្រះអាទិទេពកាមា ( KAMA ) ដែលទ្រង់ជឿជាថាបច្ចាមិត្រចង់លួចស្រឡាញ់នាង បារវាតីមហេសីរបស់ទ្រង់ ។

តាមពិតអស់លោកឃើញហើយថា ព្រះ **កាមា** តែងស្ថិតនៅ

ក្នុងសន្ដានចិត្តយើងគ្រប់គ្នា ទ្រង់ធ្វើអោយយើងយល់ដល់ការបង្កើតមនុស្សអោយបាន ច្រើននៅលើផែនដី តែទ្រង់ពុំចេះបំផ្លាញមនុស្សដូចព្រះសិវទេ » ។

មហាត្មៈពោលថែមទៀតថា ÷

«មហាបុរសក្នុងលោកតែងលើកដម្កើងនូវឆន្ទៈ មិនតបតព្រោះឆន្ទៈនេះជាទឹកអម្រិត្យ ទឹកដែលនាំពុំអោយមនុស្សស្លាប់ ហេតុដូច្នេះហើយបានថា ទេព្តានិរវេសុរ សុខចិត្តចំណាយកម្លាំង អស់ជាច្រើនឆ្នាំ ដើម្បីក្វរសមុទ្រទឹកដោះ, យកទឹកសក្ដិសិទ្ធិនេះ ។ គេតែងគោរពទន្លេគង្គា, ឪពុក ម្ដាយ និងជីដូនជីតាខ្ញុំ ក៏គោរពដូចគ្នាដែរ, ព្រោះគេជឿថា ទន្លេនេះមានលាយទឹកអម្រិត្យ ។ ឯចំណែកខ្ញុំ ក៏ខ្ញុំគោរពទឹកទន្លេនេះដូចគេឯងដែរ ព្រោះទឹកនេះត្រជាក់ដូចទឹកចិត្តខ្ញុំ បើខ្ញុំមុជទឹកទន្លេគង្គាក្នុងមួយឆ្នាំម្ដង ខ្ញុំនឹងមុជទឹកចិត្តអហិង្សារបស់ខ្ញុំរាល់ថ្ងៃ ព្រោះខ្ញុំយល់ថាជាទឹកអម្រិត្យដែលខ្ញុំពុំបាច់ធ្វើដំណើរអស់រយៈពេលវែងឆ្ងាយហើយ អស់កម្លាំងអត់ប្រយោជន៍ » ។

ចំណែកយោគពិធី ខ្ញុំស្រឡាញ់គោលដៅរបស់គេណាស់ តែខ្ញុំស្អប់មាគ៌ាដែលគេប្រាប់អោយខ្ញុំដែរ។ បើតាមខ្ញុំយល់ ចតយោគគ្មានសំលៀកបំពាក់បិតបាំងដូចកាយរបស់ខ្លួនដែរ ។ តែចិត្តអហិង្សាខ្ញុំប្រកបដោយសំលៀកបំពាក់ស្រោបជិត មើលពីក្រៅពុំឃើញឡើយ តែ

បើមើលតាមទស្សនញ្ញាណទើបឃើញ ។

លោក រ៉ុណេ ដឺ បែរវល់ ពោលថា «ពេលនោះថ្វីបើមហាឫស្សី យោគ្គិនពុំបានស្របតាមគំនិត របស់មហាត្ថះគន្ធីទាំងស្រុងយ៉ាងណាក្តី ក៏អង្គប្រជុំដែលមានតែសមាជិកបងប្អូនលោក សាស្ត្រាចារ្យកុមារានន្ទ័ និងនិស្សិតជាច្រើនយល់ថា មហាឫស្សីអង្គនេះមិនបដិសេធនូវឆន្ទៈ ប្រកបដោយសុទ្ធិដ្ឋិនិយមប្រាកដនិយម សមហេតុផលរបស់មហាត្ថះគន្ធី

ហើយបើតាមការស្រាវជ្រាវ របស់លោក រ៉ុណេ ដឺ បែរវយល់ មហាឫស្សីអង្គនេះបានត្រឡប់ មករស់នៅក្នុងគេហដ្ឋានរបស់ខ្លួនធម្មតាវិញ ហើយបានជ្រើសរើសមាគ៌ារំលត់ទុក្ខ, រំលត់កំហឹង, តាមទស្សនវិជ្ជាអហិង្សារបស់មហាត្ថះគន្ធី ៕

# មហាត្មៈគន្ធី ប្រើអហិង្សាតប និងលទ្ធិប្រកាន់វណ្ណៈទាំងបួន

លោកអាឡិចសង់ដ្រាដាវិតនីល(ALEXANDRADAVID JERL ) អ្នកនិពន្ធរឿងមហាត្មៈគន្ធីនៅក្នុងទស្សនាវដីហ្វង់អាស៊ី បានបញ្ជាក់ប្រាប់យើងថា ÷

ភារកិច្ចដ៏ធំបំផុតរបស់មហាវិរបុរសគន្ធី គឺការជីករំលើងវណ្ណៈឥណ្ឌា ដែលបានចាក់ឫសមកនៅលើដីនេះអស់ជាច្រើនជំណមនុស្ស កុំអោយមានតទៅទៀត ។

លោកដាវិតនីល បានពោលថែមទៀតថា ÷

«គោលការណ៍ដែលសំខាន់ជាងគេ គឺលោកគន្ធីត្រូវសម្រុះសម្រួលជាមួយពួកមហារាជា ( MAHARAJA ) ទាំងឡាយនៅរដ្ឋបង់ក្លាល ( BENGALE ) ព្រោះថ្វីត្បិតតែឥណ្ឌាសម័យនោះជារដ្ឋមានច្បាប់សម្រាប់ពួកសហពន្ធអនុវត្ត ហើយដាច់ចេញពីរដ្ឋស្វ័យតទាន ក៏ប៉ុន្តែអង់គ្លេសបានសង្កត់ពីលើរដ្ឋទាំងអស់នៅឥណ្ឌា ដោយឥទ្ធិពលរបស់ខ្លួន តាមរយៈសេដ្ឋកិច្ចនិងនយោបាយ ។ ប្រជាជនឥណ្ឌា

ដែលនៅក្រោមនឹមវណ្ណៈជាច្រើន សតវត្សមកហើយនោះបានទទួលការលើកទឹកចិត្តពីវណ្ណៈអភិជន ព្រោះគេត្រូវការអោយរាស្ត្រឥណ្ឌា ស៊ូទ្រាំតទៅទៀត នៅក្នុងលក្ខណៈគ្មានប្លះប្ដូរដើម្បីអោយងាយស្រួលដល់ការដឹកនាំ ។

ពួកអភិជនបានទទួលសំណោន ពីចក្រពត្រអង់គ្លេស ក្នុងការរក្សារបៀបរាបរយទាំងអស់នៅឥណ្ឌា ឯចំណែកពួកព្រាហ្មណ៍ក៏ហាក់ដូចជាមានការងារពិសេសរបស់ខ្លួន សាជាថ្មីឡើងវិញដែរ ។

សកម្មភាពរបស់អង់គ្លេស បានពង្វក់ស្មារតីប្រជាជនឥណ្ឌាអោយវង្វេង និងសម្ភារៈដែលផលិតដោយគ្រឿងចាក់ ។ គេបានលះបង់ការរវៃអំបោះដោយដៃ នឹងឈប់ប្រើថូក្អប ដែលធ្វើដោយរោងជាងក្នុងស្រុកភូមិ ហើយត្រឡប់ជានាំគ្នាទៅទិញកំណាត់សំពត់ និងក្អបថូធ្វើដោយអាលុយមីនីញ៉ូមរបស់អង់គ្លេសទៅវិញ ។

ឃើញថាប្រជាជនលះបង់ ទម្លាប់របស់ខ្លួនដែលធ្លាប់មានពីដូនតាមក ម្យ៉ាងទៀតដោយយល់ថាសត្រូវកំពុងទប់វណ្ណៈចណ្ឌាលអោយដេកត្រាំក្នុងរណ្ដៅទាសភាព ដោយដម្លើងប្រាក់បៀវត្សប្រចាំឆ្នាំអោយថែមមួយកម្រិតទៀតនោះ មហាត្មៈក៏ខំរកមធ្យោបាយដោះស្រាយ និងពន្យល់អោយប្រជាជនភ្ញាក់រលឹកនឹកឃើញផលអាក្រក់របស់ខ្លួនដែល

ដេកចាំតែប្រើរបស់ស្រាប់ៗ ហើយលះបង់ករណីយកិច្ចដ៏ល្អរបស់ខ្លួន នោះអោយយល់ការពិតឡើងវិញ ។

រដ្ឋការអង់គ្លេសយល់ដល់គោលដៅ របស់មហាត្មៈគន្ធីក៏ចាត់វិធានការណ៍យ៉ាងហ្មឺងហ្មាត់ ដើម្បីបង្រួបបង្រួមនិស្សិតបញ្ញាវ័នឥណ្ឌា អោយដើរផ្លូវខុសពីមហាក្សត្រព្រមទាំងហាមឃាត់លោកគន្ធី កុំអោយមានសិទ្ធិ ចេញចូលទៅក្នុងរដ្ឋទាំងឡាយណាដែលមានជុះគំនិតគន្ធីនិយម ឧទាហរណ៍ដូចជារដ្ឋប៉ាន់យាបជាដើម ។

ពេលនោះមហាត្មៈគន្ធី បានថយខ្លួនពីភូមិកំណើតហើយត្រឡប់ទៅតាំងអាស្រមបួសនៅមាត់ទន្លេយ៉ាមនា ( YAMUNA ) ដែលជាទីឋាន កើតនៃរឿងរបស់ធីតាប្រពន្ធលោក ។ នៅទីនោះហើយដែលគេបានដឹងថា មហាត្មបានសុំកូនស្រីក្នុងវណ្ណៈចណ្ឌាលម្នាក់យកមកធ្វើជាកូនចិញ្ចឹមរបស់លោក ។

លោកអ្នកនិពន្ធប៉ូលម៉ាសុង អួតសែល(PAULMAS SON-OURSEL ) ពោលថា÷

«នៅមាត់ទន្លេ ( YAMUNA ) ដែលជាលំនៅនៃកាបសគន្ធី គេមើលឃើញទឹកនៃទន្លេទាំងបួនហូរប្រសព្វចូលគ្នា ប្រៀបដូចជាវណ្ណៈទាំងបួន ត្រូវកំប្លាំងឥទ្ធិពលអ្វីមួយវេញ ប្រទាក់ចូលគ្នាពុំអាចបែក

បាក់បាន »

មហាត្មបានប្រមូលញាតិមិត្តជិតឆ្ងាយ អោយមកប្រជុំគ្នានៅទីនោះ ម្យ៉ាងទៀតលោកបានប្រកាសអញ្ជើញមិត្តរបស់លោកដែលមាននាទីផ្សេងៗក្នុងរដ្ឋការ ដូចជាតុលាការ អ្នកសារពតិមាន និងឈ្មួញ ឬពេទ្យហ្មជាដើម អោយមកចូលរួមក្នុងពិធីដាក់ឈ្មោះកូនស្រីចិញ្ចឹមរបស់លោក ។ ហើយនៅពេលជាមួយគ្នានោះលោកបានសម្ពោធគិលានដ្ឋានមួយនៅមាត់ឆ្នេរខ្សាច់នៃទន្លេ YAMUNA ដើម្បីព្យាបាលអ្នកជម្ងឺនៃវណ្ណៈទាំងបួន ។ ព្រហ្មវិហារធម៌របស់មហាត្មគន្ធីបាន ឮសុះសាយពេញរដ្ឋទាំងឡាយនៅឥណ្ឌា ដែលជាហេតុធ្វើអោយរដ្ឋាភិបាលអង់គ្លេសព្រួយបារម្ភជាខ្លាំង ។

ញាតិមិត្តខ្លះរបស់មហាត្មៈ ដែលពុំបានអញ្ជើញមកក្នុងពិធីនោះតែងបានផ្ញើអំណោយជាប្រាក់មានចំនួនជាច្រើនរូពី ដើម្បីជួយផ្គត់ផ្គង់ផ្ទះពេទ្យរបស់លោក ។ ពេលនេះគេសង្កេតឃើញមានគ្រួសារជាច្រើនដែលរស់នៅតាមមាត់ទន្លេ ( YAMUNA ) បាននាំគ្នាធ្វើដំណើរមកចូលរួមក្នុងពិធីដ៏មហោឡារិតនេះផង ។

មហាត្មៈគន្ធី បានប្រកាសចំពោះភ្ញៀវជិតឆ្ងាយពីបុព្វហេតុដែលលោកមានកូនស្រីមួយដ៏ល្អ ហើយលោកនិងប្រារព្ធពិធីដាក់ឈ្មោះនៅ

ពេលនេះ

លោកគន្ទីបានពោលថា ៖

បងប្អូនញាតិមិត្តទាំងឡាយ !

ក្រោយដែលខ្ញុំខំព្យាយាមធ្វើសេចក្តីល្អគ្រប់ពេលវេលា និងខំស្វត្រធម៌រំលឹកគុណព្រះរាល់ថ្ងៃមក ព្រះជាម្ចាស់ក៏បានធ្វើអំណោយមួយដល់ខ្ញុំ ។ អំណោយនោះគឺកូនស្រីដ៏ល្អនៅចំពោះមុខអស់លោករាល់គ្នានេះឯង ។ ព្រះលោកបាននាំកូនស្រីដ៏ល្អនេះ ទៅអោយកើតនៅក្នុងត្រកូលចណ្ឌាលដែលគេតែងមើលងាយគ្រប់គ្នា កាលពីសម័យមុន ។ តាមពិតត្រកូលនេះពុំមែនថោកទាប ដូចដែលទាំងអស់គ្នាជឿនោះទេ ត្រកូលចណ្ឌាលជាត្រកូលរបស់ព្រះជាម្ចាស់ ចណ្ឌាលជាកូនរបស់ព្រះជាម្ចាស់ ។ ព្រោះថាព្រះអាទិទេពព្រះអង្គ ជឿទៅលើទឹកចិត្តរបស់អ្នកទាំងនោះដែលជាបុត្រដ៏ល្អរបស់ព្រះអង្គ ។

ពួកទាំងនេះត្រូវគេធ្វើបាបជិះជាន់ តាំងពីថ្ងៃគេកើតមកម្ល៉េះ គេទាំងឡាយបានទទួលបញ្ជាពីព្រះអាទិទេព ដើម្បីចុះមកកើតជាមនុស្ស !! ព្រះអាទិទេពទ្រង់ពុំបាននឹកគិតសោះថាមានមនុស្សជាច្រើនក្រុមកូលចិត្ត យកវណ្ណកូនព្រះអង្គមកអោយធ្វើជាខ្ញុំបំរើខ្លួនសោះ ។ នេះជាការយល់ច្រឡំធ្ងន់ណាស់ !! ហេតុដូច្នេះហើយបានខ្ញុំទៅសុំយក

បុត្រីអំណោយព្រះអាទិទេពពីត្រកូលនោះមក ។

ខ្ញុំសូមអោយលោកពិចារណា ព្រមទាំងបើកភ្នែកសម្លឹងមើលអោយច្បាស់ផងថា តើកូនក្មេងតូចក្រមក់នេះវាមានទឹកមុខគួរអោយអាណិតស្រឡាញ់ ដូចដែលលោកមើលឃើញចំពោះបុត្រាបុត្រី លោកដែរឬទេ ?

ពេលនោះនាងកុមារីអាយុប្រហែលបីឆ្នាំ ប្រដាប់ដោយសំលៀកបំពាក់ស បានត្រូវគេបង្គាប់អោយដើរទៅជិតបាទាមហាត្មៈគន្ធី ហើយឱនធ្វើអភិវន្ទនកិច្ចតាមបែបឥណ្ឌា គឺយកដៃនាងទាំងពីរទៅប៉ះចុងព្រាមជើងមហាត្មៈ ហើយទើបយកដៃនោះមកច្បូតសក់នាងជាសញ្ញាសម្តែងកតញ្ញូកតវេទិរបស់កូនចំពោះឪពុករបស់ខ្លួន ។

មហាត្មៈចាប់ស្មាយុវតី ដោយដៃនាងទាំងពីរឱ្យងើបឈរឡើង ហើយទើបលោកឱបក្រសោបនាងកុមារីមកក្នុងទ្រូងរបស់លោក ។ នេះជាទំនៀមទម្លាប់របស់មាតាបិតាឥណ្ឌាដែលត្រូវសម្តែង ទៅលើបុត្រធីតានៅឱកាសប្រារព្ធពិធីបុណ្យអ្វីមួយ ឬក៏ជាករណីចំពោះមាតាបិតានិងកូននៅពេលបែកគ្នា ។

មហាត្មៈគន្ធីឆ្លៀតឱកាសនោះ ពោលទៅកាន់ភ្ញៀវទាំងឡាយថា៖«ខ្ញុំសុំឱ្យកូនស្រីតូចនេះលើកកន្ត្រៃកាត់ខ្សែបូជានិមិត្តរូបថា«ចូលេ

វណ្ណទាំង ៤បាត់រលត់ត្រឹមពីថ្ងៃនេះតទៅ » ។ ហើយម្យ៉ាងទៀតសូមឱ្យត្រកូលចណ្ឌាល យកអហិង្សាមកអនុវត្តគ្រប់ៗគ្នា ដើម្បីធ្វើតាមបណ្តាំឬបំណងរបស់ព្រះអាទិទេពដែលទ្រង់បានដៅមកពួជីថ្វាស ។ ខ្ញុំសូមដាក់ឈ្មោះកូនស្រីនេះថាជាកូន «ព្រះអាទិទេពតាំងពីពេលនេះតទៅ »

ខ្មែរបូនិមិត្តរូបបានកាត់ដាច់ ពេលណាចង្វាក់បេះដូងនៃត្រកូលចណ្ឌាលរីកឡើងញាប់ញ័ររន្ធត់ ដោយអំណាឥតព្រំដែន ។

អំពើល្អរបស់មហាត្មះគន្ធី ត្រូវគេជួយយកទៅអនុវត្តសឹងមួយចំហៀងនគរឥណ្ឌា របួតកិត្តិសព្ទសុះសាយពេញប្រទេស ។

តាំងពីពេលនោះមក មនុស្សឥណ្ឌាហាក់យល់អធ្យាស្រ័យនៃទឹកចិត្តរបស់មហាត្មគន្ធី ដែលចង់ទាញសតិសម្បជញ្ញៈមនុស្សទាំងអស់ពីការក្រេវក្រនៃលទ្ធិប្រកាន់វណ្ណៈ ។ ប្រតិបត្តិប្រឆាំងតទល់នឹងទ្រឹស្តី លោកគន្ធីបានកើតមានជាញឹកញយណាស់ដែរ ពីប្រភពពួកព្រាហ្មណ៍ និងពួកមហារាជា តែគុណធម៌របស់លោកគន្ធីត្រូវគេនាំគ្នាធ្វើតាមជឿតាមតាំងពីកាលវេលានោះមកដែរ ។

អហិង្សា របស់មហាត្មគន្ធីក្នុងការរំលាយវណ្ណបានសម្រេចជាផ្លែផ្កាយ៉ាងល្អ គឺជានៅតាមអាគារសិក្សារដ្ឋនិងឯកជនដែលពីដើម-

បើកទ្វារឱ្យតែវណ្ណៈបីមានក្សត្រ ព្រាហ្មណ៍ និងវៃស្យនោះ ក៏ចាប់ទទួលត្រកូលសូទ្រឱ្យចូលសិក្សាមួយដូចគេឯងដែរ ។ ម្យ៉ាងទៀតព្រះវិហារដែលសូទ្រត្រកូលគោរពបូជាលែងឱ្យមានចែកជាសង្កាត់ ជាក្រុមដោយឡែកដូចកាលពីពេលមុនទៀតហើយ ។ ឯចំណែកបទបញ្ញាដែលចាត់ឱ្យពួកត្រកូលសូទ្របោសសំអាត លាងព្រះវិហារចំនួនបីថ្ងៃមុនចូលទៅថ្វាយបង្គំព្រះក៏ត្រូវគេទាមទារឱ្យលប់ចោល ។ វាគ្មិនត្រកូលសូទ្រអាចបញ្ចេញយោបល់របស់ខ្លួន ក្នុងទីប្រជុំធំៗបានដោយគ្មានការហាមឃាត់ ពីសំណាក់វាគ្មិនដូចគ្នាឱ្យតែគេមើលឃើញថាការបញ្ចេញយោបល់នេះ សមហេតុផលទៅតាមនាទីរបស់ខ្លួន ។

ប្រតិកម្មជាច្រើនបានកើតឡើងពីសំណាក់ បញ្ញាវ័ន្តដូចគ្នានិងពីសំណាក់ពួកមហារាជាដែលយល់ថាសកម្មភាពរបស់មហាត្មៈគន្ធីនឹងមានគោលដៅទៅកាន់ការបះបោរបើបរិវត្តន៍ថ្ងៃណាមួយពុំខាន ។

លោកស្ហង់ហ្វីលីយូស្សា ( JEAN FILLIZAT ) បានពោលថា ÷

« គឺដោយសារទស្សនអហិង្សា ( NON - VIOLENCE ) របស់មហាត្មៈគន្ធីនេះហើយ បានជាគេសំគាល់ឃើញមានឃាតករគោមសម្លាប់មហាត្មជាញឹកញាប់ តែគេសង្កេតឃើញមានគេឃ្លាំចាំការពារ

លោកគន្ធី ពីសំណោក់ជនពាលដោយយល់ថា រូបលោកធ្វើឱ្យគេលំបាក និងតាមជួយការពារទាំងយប់ទាំងថ្ងៃនោះ លោកក៏សម្រេចចិត្តថានឹងចាកចោលទឹកដីឥណ្ឌាដើម្បីធ្វើដំណើរទៅកាន់ទ្វីបអាហ្វ្រិក ក្នុងមួយរយៈពេលសិន ។


**វាយកុំព្យូទ័រដោយ សេវាមិត្តភាព**

ផ្ទះលេខ ១៩០ អឺ ផ្សារអូរឫស្សីចាស់ (ផ្លូវសុកហុក)

មានទទួលវាយអត្ថបទ សៀវភៅសិក្សាគ្រប់ប្រភេទ

# ទស្សនវិជ្ជាអហិង្សារំដោះអាហ្វ្រិកខាងត្បូង

មានមនុស្សច្រើនណាស់ ដែលបានស្គាល់មហាត្មៈគន្ធីតែសំបកក្រៅ ។ កិច្ចការទាំងឡាយរបស់ប្រជាជនឥណ្ឌាក្នុងសម័យនោះ បានត្រូវឥទ្ធិពលចក្រពត្តិនិយមមកពីក្រៅប្រទេស ចូលទៅឈ្លានពានញាំញីស៊ីរូងដល់ជម្រៅនៃប្រមាត់បេះដូង ។ ប្រទេសកើតចលាចលវិកវរ, កល្បុកពុំបានប្រកាសអាសន្នតែខាងក្រៅប៉ុណ្ណោះទេ ថែមទាំងដុតរោលការស្រែកឃ្លានទុរ្ភិក្សខ្លោចផ្សា នៅក្នុងដែនដីឥណ្ឌាទាំងមូលថែមទៀតផង ។ ពួកបញ្ញាវ័នដែលមើលឃើញច្បាស់នូវសភាពព្រៃផ្សៃរបស់សត្រូវ តាមរយៈសកម្មភាពដ៏កម្រោលបាននាំគ្នាស្រែកបង្ហូក, ទូងស្គរវាយឃ្មោះបង្អើលសម្បជញ្ញៈអ្នកស្នេហាជាតិ គ្រប់ស្រទាប់វណ្ណៈឱ្យស្ទុះភ្ញាក់ឡើងគ្រប់គ្នាកាន់ដំបងលំពែងវាយ បំបែកក្បាលសត្រូវរួមដែលមានគំនិតចង់លេបទឹកដីរបស់ម្ចាស់ស្រុក ។ មហាត្មៈគន្ធីស្ថិតក្នុងសភាព ចង្អៀតចង្អល់ឯកហាក់ដូចជាពុំចង់បែកឃ្លាតពីភូមិកំណើតរបស់ខ្លួនបន្តិចសោះឡើយ ។

ក្រោយដែលបានសូត្រធម៌ នៅពេលល្ងាចរួចស្រេចបាច់អស់

ហើយ លោកក៏ចាប់សរសេរសំបុត្រទុកឱ្យមិត្តភ័ក្ត្ររបស់លោក ដើម្បីជាឥវ៉ាន់ផ្ញើដល់មិត្តភ័ក្រទាំងនោះពីការបែកឃ្លាតរបស់លោកនៅពេលនេះ ។

លុះសរសេររួចហើយមហាត្មៈ ក៏កាន់យកទៅផ្ញើនឹងយុវនិស្សិតម្នាក់ឈ្មោះ «ចន្ទ្រ - បុស្ស» ដែលធ្លាប់បានទទួលការសិក្សាអក្សរសាស្ត្រទស្សនវិជ្ជាជាញឹកញយនៅអាស្រមរបស់លោក ។

លោករ៉ូមាំង រ៉ូឡង់ កំពូលអ្នកសរសេរជីវប្រវត្តិរបស់មហាត្មៈគន្ធីបានពោលប្រាប់យើងថា ÷

«សេចក្ដីសំបុត្ររបស់មហាត្មៈគ្មានអ្វីជាការអាថ៌កំបាំងសម្រាប់ផ្លូវនយោបាយរបស់ឥណ្ឌាក្នុងសម័យនោះទេ តែគេបានប្រទះឃើញនៅក្នុងន័យ នៃសំបុត្រនោះពីមនោសញ្ចេតនារបស់ទស្សនវិទូម្នាក់ ដែលស្រឡាញ់មិត្តភ័ក្រ នឹងប្រទេសជាតិជាងជីវិតខ្លួនទៅទៀត»

លោករ៉ូមាំង រ៉ូឡង់ពោលថែមទៀតថា ÷

«សំបុត្ររបស់មហាត្មៈគន្ធី បានត្រកូលយុវនិស្សិត «ចន្ទ្រ-បុស្ស» យកទៅប្រគល់ដល់ដៃមិត្តភ័ក្រ របស់លោកហើយដែលមិត្តរបស់មហាត្មៈឈ្មោះតាគួរ ( TAGORE ) រក្សាទុករហូតមក ។

« ពេលវេលាជួនកាលមានតម្លៃស្មើ និង ភ្នំមាស ភ្នំពេជ្រ ដែលអ្នកប្រាជ្ញចាត់ទុកថាពុំអាចកាត់តម្លៃបាន » ក៏ប៉ុន្តែជួនកាលពេលវេលានេះវិញ មានតម្លៃពុំបានស្មើនិងតម្លៃ ស្រោមសំបុត្រមួយផង !! នេះជាគំនិតរបស់មិត្តភក្ដិក្រុមមហាត្មៈគន្ធីគ្រាដែលព្រាត់ប្រាស ហើយដែលគេពុំបានលោត្មានេវិញទៅមកនៅគ្រាក្រោយបង្អស់ ។

លោកតាគួរឱបសំបុត្ររបស់មហាត្មៈ ទុកនៅក្នុងដើមទ្រូងលោកជានិច្ច, សំបុត្រនេះលោកបានយកមកអាននៅឱកាសដែលមានបញ្ហាអ្វីមួយពិបាកដោះស្រាយចោទមកលើលោក ។

តាមពាក្យរបស់លោកតាគួរ ( TAGORE ) ដែលបានបកស្រាយនៅចំពោះប្រិយមិត្តទាំងឡាយរបស់លោក ក្នុងឱកាសឈាបនកិច្ចសាកសព ចាងហ្វាងសារពត៌មានម្នាក់ដែលស្លាប់ដោយសត្រូវលួចធ្វើឃាត លោកតាគួរថ្លែងថា÷

« ខ្ញុំពុំបាននៅជាមួយលោក [illegible] តែងសេចក្ដីក្នុងសំបុត្ររបស់លោកហាក់ធ្វើអោយភ្ញាក់រលឹក [illegible] ដល់មាតាដីប្លែមួយដែលពុំត្រូវការ «[illegible]» បើសិនជាបានកបប្រសើរមែន, ខ្ញុំជឿថា[illegible] ព្រោះថាលទ្ធិមិនតបតពុំត្រូវការស្លាបហើយ (LA NON-VIOLENCE N'A PAS BESOIN

D'AILES )

ក៏ប៉ុន្តែការអត់ធ្មត់របស់លទ្ធិនេះ ពុំបានប្រើពេលឱ្យហួសកំណត់រហូតដល់ទៅបើកដៃឱ្យស្តេចមក្កុរាជ្យអន្ទងព្រលឹង ឬបោះដៃមកឈោងចាប់ទាន់ឡើយ !

គោលការណ៍សំខាន់ៗ នៃលទ្ធិនេះមានមាគ៌ាសំរាប់ដើរជាកំណត់ណាស់, ខ្ញុំជឿថាបើយើងហ៊ានអនុវត្តនូវគំរោងការនេះយើងមានមិត្តដ៏ល្អមួយ ជាជំនួយដល់យើងព្រោះថាបើគេ ( មហាត្មះគន្ធី) ពុំបាននៅជិតយើងក៏ពិតមែនក៏ប៉ុន្តែសម្លេងគេ, ទឹកចិត្តគេនៅជិតយើងជារាប » ។

លោកតាត្អូវនិយាយដល់ត្រឹមវគ្គនេះ ក៏បញ្ចេញសំបុត្ររបស់មហាត្មះគន្ធីឱ្យមិត្តលោកទាំងអស់គ្នា ដែលនៅទីនោះអានម្នាក់ម្តងៗគ្រប់គ្នា ។ សេចក្តីក្នុងសំបុត្ររបស់មហាត្មះគន្ធីបានត្រូវលោករុទ្យប់យកមកបកប្រែក្នុងទស្សនាវដ្តីប្រាំង់អាស៊ី ( FRANCE ASIE ) ហើយមានគំនិតខ្លះបានចូលលាយឡំទៅនិង ទស្សនវិជ្ជាផ្ទាល់របស់លោកតែម្តង ។

សេចក្តីក្នុងសំបុត្រមានដូចតទៅនេះ ÷

«ពេលនេះខ្ញុំពុំអាចនិងជំរាបមិត្តទាំងអស់ ឱ្យសព្វគ្រប់ពីបុព្វ

ហេតុដែលធ្វើឱ្យខ្ញុំលាមិត្តមួយរយះពេលសិនបានទេ ខ្ញុំជឿថាមិត្តបានដឹងជាងខ្ញុំទៅទៀត ពីរឿងដែលអ្នកកាន់ការប្រទេសយើង (ឥណ្ឌា) សម្រេចអោយគេតាមចាប់ខ្ញុំ ។ ខ្ញុំពុំខ្លាចគុកទេ ! ខ្ញុំស្រឡាញ់គុកណាស់ព្រោះទីនោះខ្ញុំបានជួបប្រទះនិងទិដ្ឋភាពប្លែកៗ ដែលពិភពលោកបច្ចុប្បន្នសន្មតថាជា (កន្លែងសម្រាប់ផ្សាំងមនុស្ស ។ ( LIEU OU L'ON DOMPTE LES FAUTIFS )

ខ្ញុំស្តាយប្រទេសឥណ្ឌាជាងខ្ញុំស្តាយជីវិតខ្ញុំទៅទៀត បើប្រទេសឥណ្ឌាពុំបានសេរីភាព ឯករាជ្យ សន្តិភាពទេ ខ្ញុំនឹងពុំព្រមផ្លាស់វិចារណញ្ញាណ ដែលខ្ញុំបានសម្រេចថានិងអនុវត្តនោះឡើយ ។ មិត្តទាំងអស់បាននាំឱ្យខ្ញុំប្រើកម្លាំងដើម្បីតបតនឹងសត្រូវ ខ្ញុំពុំបានបដិសេធនូវគំនិតទាំងនេះទេ ព្រោះ ÷

«គេប្រើកម្លាំងដើម្បីទប់ក្បាលរថភ្លើង» ក៏ប៉ុន្តែខ្ញុំយល់ថា ÷

«ការធ្វើ កុំឱ្យក្បាលរថភ្លើងដើរខុសគ្នា ប្រសើជាង ការខំទប់កម្លាំង ដ៏មហិមានៃក្បាលគ្រឿងចក្រនេះ »

ខ្ញុំសម្រេចថានិងធ្វើដំណើរ ចូលទៅរស់ក្នុងស្រុកនោះ ( អាហ្វ្រិកខាងត្បូង ) ព្រោះខ្ញុំដឹងថាមានមនុស្សប្រមាណជាងដប់ម៉ឺននាក់កំពង់ត្រូវមនុស្សដូចគ្នាជិះជាន់ ។ បើខ្ញុំសម្រេច ឬពុំបានសម្រេច

បំណងយ៉ាងណា សូមឱ្យមិត្តទាំងអស់គ្នាដោះស្រាយវិបត្តិប្រទេសឥណ្ឌាតាមទស្សនអហិង្សា ទស្សនដែលមហាបុរសនៅឥណ្ឌាជំនាន់មុនបាន = ធ្លាប់យកមកប្រើប្រាស់នៅលើដីចាស់នេះ ។ សូមអោយមិត្តពិចារណាថា ប្រទេសឥណ្ឌាពេលនេះពុំបានស្ថិតនៅលើកិត្តិសព្ទដូចជាសរសេរថ្មព្រះបាទអសោក ( ASOKA ) ការពារដោយសីហៈនោះឡើយ ដូច្នេះគោរក្ខកម្មបានពឹងផ្អែកទាំងស្រុង ទៅលើទឹកចិត្តដ៏ត្រជាក់របស់ក្មេងគង្វាល និងវាលស្មៅខ្ចីនោះឯង ។

លុះអានសេចក្តីសំបុត្ររបស់មហាត្មចប់កាលណា គេម្នាក់ៗហាក់ដូចជាមើលឃើញជើងមេឃថ្មីមួយដែលត្រូវយកមកដោះស្រាយគ្រប់គ្នា ។

សូមជំរាបថា ក្រោយពេលដែលមហាត្មគន្ធីធ្វើដំណើរចាកចោលដីឥណ្ឌាទៅ គេសង្កេតឃើញមានកើតគំរោងការថ្មីមួយនៅគ្រប់ច្រកល្ហកនៃទីប្រជុំជននានា ។ អ្នកដែលដឹកនាំគំរោងការនេះគឺនិស្សិត «ចន្ទ្រ- បុស្ស» ដែលជាសាវ័កផ្ទាល់របស់មហាត្មគន្ធីតែម្តង ។ រដ្ឋការអង់គ្លេសបានប្រើគ្រប់មធ្យោបាយ ដើម្បីទប់ទល់និងប្រតិកម្មនេះដោយរួបរួមជាមួយនិងមហារាជា ( MAHARAJA ) ឥណ្ឌាទាំងឡាយ ។

យើងក្រឡេកមើលសកម្មភាពរបស់មហាត្មៈគន្ធីម្តងវិញ ។ នៅ

ឆ្នាំ ១៨៩៣ នាទីក្រុងអាហ្វ្រិកមួយឈ្មោះក្រុងប្រេតូរិយ៉ា គេមើលឃើញមនុស្សម្នាក់ ប្រដាប់ដោយសំលៀកបំពាក់សស្អាតដើរដោយជើងទទេ, ពីទីមួយទៅទីមួយសព្វគ្រប់ច្រកល្ហកនៃទីក្រុង ។ មនុស្សដដែលនេះជួនកាលមានការិយាល័យធ្វើការនៅក្នុងមហាវិទ្យាល័យនានា ជួនកាលទៀតមានឋានៈទីជាអ្នកទទួលបោះពុម្ពសៀវភៅ ឬសារពត៌មាន ជួនកាលទៀត មានឋានៈទីជាអ្នកជួយផ្តល់ពត៌មានដល់អ្នកកាន់រដ្ឋនានាក្នុងក្រុង ។

នៅលើក្របសៀវភៅផ្សេងៗ ដែលច្រើនស្តីពីបញ្ហានយោបាយនិងសាសនា គេតែងបានឃើញរូបមនុស្សនេះគ្រឹមពាក់កណ្តាលខ្លួនលំអក្របខាងក្រៅ ។

ជននោះជាមហាត្មៈគន្ធី, លោកជាមនុស្សមានមាឌស្គម តែធ្វើការឥតចេះហត់ ។ នៅផែនដីអាហ្វ្រិកមហាត្មៈ មានមុខងារច្រើនយ៉ាងនិងបំពេញ ។ លោកជាអ្នកសារពត៌មាន ជាវាគ្មិនសម្រុះសម្រួលវិបត្តិអាហ្វ្រិក រវាងជាតិស្បែក ស និង ស្បែកខ្មៅ លោកជាគ្រូបង្រៀននៅមហាវិទ្យាល័យ ជាពប្ជូញលក់ទស្សនាវដ្តីផ្សេងៗ ជាសមាជិកសហគ្រិនសំណាងរបស់រដ្ឋការអាហ្វ្រិក ជាគ្រូហ្វឹកខាងវិធីព្យាបាលសាមញ្ញ និងជាហោរាសាស្រ្តដ៏ចំណាន ។ តាមសំដីរបស់លោក

OURSEL ថា «មហាត្មៈគន្ធីជាគ្រូទាយខាងក្បួនទព្វគ្រោះ ប្រចាំថ្ងៃយ៉ាងសក្តិសិទ្ធិ តែលោកពុំមែនជាហោរាជើរ =ទស្សន៍ទាយជា សាធារណៈនោះទេ ។ ពេលណាទំនេរលោកតែងពន្យល់ពីក្បួនទាយ នវគ្រហ ( NAVAGRAHA ) ដែលនិយាយពីដំណើរផែនដី ឬដំណើរពិតខាងអវកាសទាក់ទងទៅនិងសាសនានានាក្នុងគម្ពីរវេទ អោយសមាជិកគ្រួសារអ្នកផ្ទះស្តាប់ ។

យើងសូមជម្រាបថាមហាត្មៈ បានរស់នៅជាមួយមិត្រលោកម្នាក់ ដែលធ្លាប់ស្គាល់ទាក់ទងគ្នាទៅវិញទៅមកខាងផ្លូវជំនួញនៅឥណ្ឌា ហើយដែលធ្លាប់ចូលរួមធ្វើកុប្បកម្មជាមួយគ្នាតទល់និងមហារាជានៅបង់ហ្គាល ( BENGALE ) ។

នៅទីនោះមហាត្មៈបានបើបឈរយ៉ាងសកម្ម ប្រឆាំងនិងរដ្ឋការអាហ្វ្រិក ដែលដម្លើងប្រាក់ពន្ធដារ ទៅលើប្រជារាស្ត្រស្បែកខ្មៅ ។ លោកបានសុំទាមទារដល់អ្នករដ្ឋការក្នុងទីក្រុង ពីបញ្ហាប្រាក់បៀវត្សដែលជនជាតិឥណ្ឌាស្បែកខ្មៅបានទទួលពីសំណាក់អង្គការរដ្ឋ និងអង្គការឯកជននានាក្នុងទីក្រុង ។

សូមជំរាបថាពួកឥណ្ឌាស្បែកខ្មៅមានចំនួនរាប់ម៉ឺននាក់ បានរស់នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ពួកនេះពុំបានទទួលសេរីភាពដូច